**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ២៤ សសរ**

# សេចក្តីសម្រេច
# ស្តីពី
# ការកែសម្រួលសមាសភាពរបស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញសេចក្តីសម្រេចលេខ ១៥០ សសរ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម។

-បានឃើញសេចក្តីសម្រេចលេខ ៩១ សសរ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាល ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម។

-យោងតាមសំណូមពរការងារចាំបាច់

## សម្រេច

**ប្រការ ១.-**

ត្រូវបានកែសម្រួលសមាសភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់ មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម ដែលបានកំណត់ដោយសេចក្តីសម្រេចលេខ ៩១ សសរ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ដូចមានរាយនាមខាងក្រោម៖

១-ឯកឧត្តម នាយឧត្តមសេនីយ៍ **ផៀច សុផាន់ណា** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ប្រធាន

២-ឯកឧត្តម **ម៉ុក ម៉ាន់នី** អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ អនុប្រធាន

៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក **គីម ជាតិ** អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ អនុប្រធាន

៤-ឯកឧត្តម ឧត្តមសេនីយ៍ឯក **សរ សិទ្ធិ** អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ អនុប្រធានអចិន្ត្រៃយ៍

៥-ឯកឧត្តម **សុខ សារេត** អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ អនុប្រធាន

៦-ឯកឧត្តម ឧត្តមសេនីយ៍ឯក **សោម ច័ន្ទឌីណា** អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ អនុប្រធាន

៧-លោកជំទាវ **ជី សារី** ទីប្រឹក្សាក្រសួងមហាផ្ទៃ អនុប្រធាន

៨-ឯកឧត្តម ឧត្តមសេនីយ៍ឯក **សោម សោភ័ណ្ឌ** អនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អនុប្រធាន

៩-ឯកឧត្តម ឧត្តមសេនីយ៍ឯក **អ៊ិន ម៉ូរ៉ា** អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អនុប្រធាន

១០-ឯកឧត្តម **ឌួច ធីរៈ** អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ សមាជិក

១១-ឯកឧត្តម **ម៉ែន សាម៉ន** អនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន សមាជិក

១២-លោកជំទាវ **ឃុន ចេនា** អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា សមាជិកា

១៣-លោកជំទាវ **ចាន់ ផលធឿន** អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិកា

១៤-ឯកឧត្តម **គីម ហាសសុខសីហា** អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម សមាជិក

១៥-ឯកឧត្តម នាយឧត្តមសេនីយ៍ **ឃុន សំបូរ** អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ សមាជិក

១៦-ឯកឧត្តម ឧត្តមសេនីយ៍ឯក **គាន់ សុខមិជ្ជា** ប្រធានលេខាធិការដ្ឋាន នៃ គ.ប.ផ.ក សមាជិក

១៧-ឯកឧត្តម ឧត្តមសេនីយ៍ឯក **អន សុខុន** មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

១៨-ឯកឧត្តម **អ៊ូច ឡូច** ទីប្រឹក្សាក្រសួងមហាផ្ទៃ សមាជិក

១៩-ឯកឧត្តម **ឈី ហុច** ទីប្រឹក្សាក្រសួងមហាផ្ទៃ សមាជិក

| | | |
|---|---|---|
| ២០-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ចាន់ ច័ាន់ធឿន** | | ប្រធាននាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច នៃអគ្គស្នងការដ្ឋាននគរបាលជាតិ **សមាជិក** |
| ២១-លោក | **កែម សុខឃាង** | អគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា **សមាជិក** |
| ២២-លោកឱសថការី | **ហ៊ុន ហួង** | អគ្គនាយករងបច្ចេកទេសសុខាភិបាល នៃក្រសួងសុខាភិបាល **សមាជិក** |
| ២៣-លោក | **អូន ពិសាល** | អគ្គាធិការរង នៃក្រសួងយុត្តិធម៌ **សមាជិក** |
| ២៤-លោក | **ឌិន ចំរើន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំនៃក្រសួងពាណិជ្ជកម្ម **សមាជិក** |
| ២៥-លោក | **អ៊ិន សំអូរ** | អនុប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ **សមាជិក** |
| ២៦-លោកវរសេនីយ៍ទោ | **ឯម ឌុន្នីន៍** | ប្រធានមន្ទីរពិសោធន៍ផលិតផលក្លែងក្លាយ នៃក្រសួងមហាផ្ទៃ **សមាជិក** |
| ២៧-លោកឱសថការី | **ហួត សេងឌុង** | អនុប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង នៃក្រសួងសុខាភិបាល **សមាជិក** |
| ២៨-លោក | **ម៉ោង សារិទ្ធ** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ **សមាជិក** |

**ប្រការ ២.-**

តួនាទី ភារកិច្ច របស់សមាសភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវអនុវត្តតាមសេចក្តីសម្រេចលេខ ១៥០ សសរ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម។

**ប្រការ ៣.-**

សេចក្តីសម្រេចលេខ ៩១ សសរ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាល ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ អង្គារ ១១កើត ខែ ចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ